# ក្រដាសចម្លើយជំពូកទីពីរ

សូមបំពេញចន្លោះខាងក្រោម៖

ឈ្មោះ……………………………………………………………………………………………………

លេខរៀងសិស្ស………………………………………………………………………………………

(ទុកចន្លោះចោលប្រសិនជាអ្នកមិនស្គាល់លេខរបស់អ្នក។)

អាសយដ្ឋាន…………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

ប្រទេស……………………………………………………………………………………………………

## ការណែនាំ

ពេលអ្នកបានបញ្ចប់ការសិក្សាមេរៀននីមួយៗរបស់អ្នក សូមបំពេញក្រដាសចម្លើយការវាយតម្លៃតាមជំពូក។ សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយមួយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។ ចូរដាក់ពណ៌ខ្មៅសម្រាប់ចម្លើយដែលអ្នកបានជ្រើសរើស។ *សូមប្រាកដថា លេខដែលនៅលើក្រដាសចម្លើយ គឺដូចគ្នានឹងលេខនៃសំណួរដែលអ្នកកំពុងតែឆ្លើយ។*

*ឧទាហរណ៍*

១. ការកើតជាថ្មីមានន័យថា

ក) នៅវ័យក្មេង។

ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។

គ) ចាប់ផ្តើមឆ្នាំថ្មី។

ចម្លើយត្រឹមត្រូវគឺ **ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ**។ ដូច្នេះ អ្នកគួរតែដាក់ពណ៌ខ្មៅ ⓧ ខ ដូចនេះ៖

១. (ក) ● (គ) (ឃ)

*សូមបើកទំព័របន្ទាប់មួយទៀត នៅពេលអ្នកចង់ចាប់ផ្តើម។*

# ក្រដាសចម្លើយជំពូកទីពីរ

សូមដាក់ពណ៌ខ្មៅ នៅកន្លែងដែលត្រឹមត្រូវដោយប្រុងប្រយ័ត្ន សម្រាប់លេខនីមួយៗ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១. | ក | ខ | គ | ឃ | ១១. | ក | ខ | គ | ឃ |
| ២. | ក | ខ | គ | ឃ | ១២. | ក | ខ | គ | ឃ |
| ៣. | ក | ខ | គ | ឃ | ១៣. | ក | ខ | គ | ឃ |
| ៤. | ក | ខ | គ | ឃ | ១៤. | ក | ខ | គ | ឃ |
| ៥. | ក | ខ | គ | ឃ | ១៥. | ក | ខ | គ | ឃ |
| ៦. | ក | ខ | គ | ឃ | ១៦. | ក | ខ | គ | ឃ |
| ៧. | ក | ខ | គ | ឃ | ១៧. | ក | ខ | គ | ឃ |
| ៨. | ក | ខ | គ | ឃ | ១៨. | ក | ខ | គ | ឃ |
| ៩. | ក | ខ | គ | ឃ | ១៩. | ក | ខ | គ | ឃ |
| ១០. | ក | ខ | គ | ឃ | ២០. | ក | ខ | គ | ឃ |

នេះជាការបញ្ចប់នៃតម្រូវការសម្រាប់ជំពូកទី២។ សម្រាប់ពិន្ទុ សូមផ្ញើក្រដាសចម្លើយជំពូកទី២ ទៅឱ្យគ្រូរបស់អ្នក ឬក៏ ទៅការិយាល័យដែលនៅក្នុងតំបន់របស់អ្នក។

សម្រាប់ប្រើនៅការិយាល័យនៃសកល
វិទ្យាល័យ គួបល ប៉ុណ្ណោះ

ថ្ងៃទី…………………………………………

ពិន្ទុ…………………………………

PN 05.13

## ការវាយតម្លៃជំពូកទី២

១ គោលការណ៍តាមព្រះគម្ពីរមិនដូចគោលការណ៍តាមលោកិយ៍ទេ ចំពោះការសម្រេចចិត្តដែលធ្វើឱ្យគាប់ព្រះទ័យ

ក) ព្រះជាម្ចាស់។

ខ) មនុស្សផ្សេងទៀត។

គ) ខ្លួនឯង។

២ ការសិក្សាគំរូផ្សេងៗតាមព្រះគម្ពីរស្ដីពីអាកប្បកិរិយាដែលព្រះជាម្ចាស់សព្វព្រះទ័យ ឬ មិនសព្វព្រះទ័យឱ្យយើងមាន គឺជាវិធីមួយនៃការរកឃើញ

ក) រង្វាស់នៃភាពជោគជ័យនៅក្នុងសម័យកាលព្រះគម្ពីរ។

ខ) វីរបុរសក្លាហានដើម្បីថ្វាយបង្គំ និងដើម្បីយកតម្រាប់តាម។

គ) គោលការណ៍តាមព្រះគម្ពីរសម្រាប់ធ្វើការសម្រេចចិត្ត។

៣ ក្នុងកណ្ឌគម្ពីរ ម៉ាថាយ ជំពូក២៥ ដំណើររឿងអំពីអ្នកបម្រើបីនាក់ ជាឧទាហរណ៍បំភ្លឺអំពីគោលការណ៍

ក) មនុស្សមួយចំនួនមានជីវិតពិបាកជាងអ្នកដទៃ។

ខ) យើងគួរតែប្រើអ្វីដែលព្រះជាម្ចាស់ប្រទានឱ្យយើងឱ្យបានត្រឹមត្រូវ។

គ) រឿងចេញពីព្រះគម្ពីរគួរឱ្យចាប់អារម្មណ៍។

៤ «ការមកយកឋានៈជាទាសករ» (ភីលីព ២:៧) ព្រះយេស៊ូក្លាយជា

ក) ទាសកររបស់មនុស្ស និងមិនមែនជាអ្នកគ្រប់គ្រងដ៏មានអំណាចទេ។

ខ) អ្នកជំនួយរបស់ព្រះជាម្ចាស់ក្នុងការបង្កើតផែនដី។

គ) បុរសម្នាក់ដែលបម្រើអ្នកមានតែប៉ុណ្ណោះ។

៥ ពេលយើងនិយាយថា ព្រះគ្រិស្ដគ្រប់ល័ក្ខក្នុងគ្រប់ការទាំងអស់។ ពាក្យថា គ្រប់ល័ក្ខ ភ្ជាប់គ្នានឹងពាក្យ

ក) ភាពបរិសុទ្ធ។

ខ) រូបរាងខាងក្រៅ។

គ) ភាពវៃឆ្លាត។

៦ ការគោរពរូបកាយរបស់យើងដែលជាព្រះវិហាររបស់ព្រះគឺបង្ហាញដោយផលផ្លែនៃព្រះវិញ្ញាណ ហៅថា

ក) អំណួត។

ខ) ការចេះទប់ចិត្តខ្លួនឯង។

គ) ភាពអាត្មានិយម។

៧ ការណែនាំតាមព្រះគម្ពីរស្នើថា នៅពេលដែលគ្រិស្តបរិស័ទអភិវឌ្ឍចិត្តគំនិតរបស់គេតាមរយៈការសិក្សាព្រះគម្ពីរ គេនឹងលូតលាស់

ក) កាន់តែចេះអាន និងសរសេរ។

ខ) ខាងប្រាជ្ញា។

គ) ខាងមានឥទ្ធិពល។

៨ ការលូតលាស់ខាងវិញ្ញាណកើតឡើងពេលគ្រិស្តបរិស័ទ

ក) ព្រងើយកន្តើយនឹងរាងកាយ។

ខ) សិក្សាបន្ថែមអំពីវីរបុរសដ៏អស្ចារ្យ។

គ) ស្តាប់ និងចុះចូលការបង្រៀនរបស់អ្នកដឹកនាំដែលមិនជឿព្រះ។

៩ ប្រសិនបើយើងលូតលាស់ក្នុងព្រះគុណរបស់ព្រះជាម្ចាស់ យើងត្រូវតែ

ក) ស្តាប់យ៉ាងយកចិត្តទុកដាក់នូវអ្វីដែលអ្នកដទៃប្រាប់យើងឱ្យធ្វើ។

ខ) អានខគម្ពីរ និងការអធិស្ឋានក្នុងពិធីពិសេសៗ។

គ) យកចិត្តទុកដាក់នឹងការបង្រៀនល្អ ព្រមទាំងការអានព្រះគម្ពីររាល់ថ្ងៃ។

១០ ការប្រព្រឹត្តដោយប្រាជ្ញា និងគោរពចំពោះអ្នកមិនជឿ គឺមានន័យថា

ក) កើនប្រជាប្រិយភាពក្នុងចំណោមពួកគេ។

ខ) ការបង្ហាញការយកចិត្តទុកដាក់ចំពោះពួកគេ។

គ) ពង្រីកក្រុមមិត្តភក្តិ។

១១ សារសំខាន់នៃភាពរួបរួមក្នុងគ្រួសារព្រះជាម្ចាស់ គឺផ្តោតសំខាន់ទៅលើ

ក) ការអធិស្ឋានរបស់ព្រះយេស៊ូក្នុងកណ្ឌគម្ពីរ យ៉ូហាន ជំពូក១៧។

ខ) ការអធិស្ឋានរបស់ព្រះអម្ចាស់ក្នុងកណ្ឌគម្ពីរ ម៉ាថាយ ជំពូក៦។

គ) សុភមង្គល ក្នុងគម្ពីរ ម៉ាថាយ ជំពូក៥។

១២ គន្លឹះនៃភាពមិនចុះសំរុងគ្នាក្នុងក្រុមជំនុំ ដែលកណ្ឌគម្ពីរយ៉ាកុបវែកញែកគឺ

ក) បញ្ជីសមាជិកភាព។

ខ) ការប្រកាន់ពូជសាសន៍។

គ) ការលូតលាស់របស់ក្រុមជំនុំ។

១៣ គំរូមួយរបស់សមាជិកក្នុងគ្រួសារព្រះជាម្ចាស់ដែលរំពឹងនឹងបំពេញតាមក្រឹត្យវិន័យនៃសេចក្ដីស្រឡាញ់ គឺត្រូវ

ក) រិះគន់គ្រូគង្វាលចំពោះការខ្វះសេចក្ដីស្រឡាញ់របស់ពួកគាត់។

ខ) អញ្ជើញតែភ្ញៀវសំខាន់ៗរបស់ក្រុមជំនុំមកលេងផ្ទះរបស់អ្នក។

គ) ជួយគ្រួសារគ្រិស្តបរិស័ទដែលជាប់គុក ដោយព្រោះតែសេចក្ដីជំនឿរបស់ពួកគាត់។

១៤ ការបម្រើព្រះកាយរបស់ព្រះគ្រិស្ត គួរតែជា

ក) ប្រាប់បញ្ហានានារបស់សមាជិកជាច្រើន។

ខ) ប្រាប់ភ្ញៀវថ្មីក្នុងព្រះវិហារអំពីកំហុសរបស់គេ។

គ) អញ្ជើញនរណាម្នាក់ដែលឯកាទៅលេងផ្ទះអ្នក។

១៥ ក្នុងនាមអ្នកគ្រប់គ្រងល្អអំណោយទានខាងវិញ្ញាណរបស់មនុស្សម្នាក់ និងសមត្ថភាពមកពីធម្មជាតិ ប្រតិបត្តិ

ក) ភាពពេញវ័យ។

ខ) ភាពអាត្មានិយម។

គ) ការប្រណែនឈ្នានីស។

១៦ គម្ពីរយោងរបស់ព្រះយេស៊ូចំពោះអ្នកជឿ ជាអំបិលនៃផែនដីស្មើថា

ក) ព្រះយេស៊ូចូលចិត្តអាហាររសជាតិប្រៃ។

ខ) យើងត្រូវរក្សាព្រះវត្តមានរបស់ព្រះក្នុងសង្គមរបស់យើង។

គ) អ្នកជឿត្រូវតែបរិភោគអាហារគ្មានជាតិប្រៃ។

១៧ គ្រិស្តបរិស័ទបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងមានប្រសិទ្ធិភាព តាមរយៈ

ក) ការដកស្រង់ព្រះបន្ទូលជាច្រើនក្នុងព្រះគម្ពីរ។

ខ) ការបំពេញតម្រូវការរបស់អ្នកដទៃ។

គ) ការរិះគន់អ្នកមិនជឿ។

១៨ ពេលយើងឃើញភាពអយុត្តិធម៌ក្នុងសហគមន៍របស់យើង យើងគួរតែ

ក) ប្រើគ្រប់មធ្យោបាយដើម្បីបង្ខំឱ្យអ្នកធ្វើអាក្រក់ផ្លាស់ប្ដូរមាគ៌ារបស់គេ។

ខ) ព្រងើយកន្តើយនឹងវា ពីព្រោះគ្រិស្តបរិស័ទមិនសមរស់នៅក្នុងលោកិយ៍ឡើយ។

គ) ធ្វើអ្វីដែលអាចធ្វើទៅបានស្របតាមការដឹកនាំរបស់ព្រះគម្ពីរ។

១៩ ការបង្ហាញសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់ទៅកាន់លោកិយ៍តម្រូវឱ្យមាន

ក) ការសម្ដែងចេញផលផ្លែនៃព្រះវិញ្ញាណ។

ខ) ការធ្វើការងារអន់ៗក្នុងព្រះវិហារ។

គ) ការរៀននៅសាលាព្រះគម្ពីរ។

២០ ការផ្សព្វផ្សាយព្រះបន្ទូលព្រះទៅកាន់លោកិយ៍រួមមាន

ក) ការចែកចាយទីបន្ទាល់ល្អៗ។

ខ) ការជជែកវែកញែករហូតដល់ពួកគេផ្លាស់ប្រែចិត្តគំនិត។

គ) ការឆ្លើយតបទៅនឹងការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

សូមប្រគល់*ក្រដាសចម្លើយស្ដីពីជំពូកទី២* របស់អ្នកទៅគ្រូបង្រៀនអ្នក។ ឥឡូវនេះ ដោយព្រោះអ្នកបានបញ្ចប់ការសិក្សានៃមុខវិជ្ជានេះហើយ សូមសួរទៅកាន់គ្រូបង្រៀនអ្នក ដើម្បីផ្ដល់អនុសាសន៍អំពីការសិក្សាមុខវិជ្ជាផ្សេងមួយទៀត។